# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការពារជាតិ**

# ញត្តិគាំទ្រ

យើងខ្ញុំទាំងអស់គ្នា តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និង ពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមគាំទ្រទាំងស្រុង និងយ៉ាងពេញទំហឹងចំពោះលទ្ធផលនៃការផ្ទៀងផ្ទាត់ផែនទី ដែលរដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង តាមរយៈស្ថានទូតបារាំងបាននាំយកមកប្រគល់ជូនរាជរដ្ឋាភិបាលកម្ពុជា ធ្វើការផ្ទៀងផ្ទាត់នាថ្ងៃទី ០៣ ខែកញ្ញា ឆ្នាំ២០១៥ នៅវិមានសន្តិភាព ជាមួយផែនទីផ្លូវការ និងស្របច្បាប់របស់រាជរដ្ឋាភិបាលកម្ពុជាដែលកំពុងប្រើបច្ចុប្បន្ន និងផែនទីរបស់រដ្ឋាភិបាលនៃសាធារណរដ្ឋបារាំង ឃើញថាមានភាពដូចគ្នាបេះបិទ និងដូចគ្នានឹងផែនទីរបស់អង្គការសហប្រជាជាតិដែលបានធ្វើការផ្ទៀងផ្ទាត់នាពេលកន្លងមក ដែលនេះបានបង្ហាញយ៉ាងច្បាស់អំពីភាពត្រឹមត្រូវពិតប្រាកដនៃផែនទីដែលរាជរដ្ឋាភិបាលកម្ពុជាបាននិងកំពុងប្រើប្រាស់ក្នុងការកំណត់ព្រំដែនរវាងកម្ពុជានិងវៀតណាម និងបង្ហាញឲ្យឃើញកាន់តែច្បាស់ថែមទៀតអំពីនយោបាយបោកប្រាស់របស់ក្រុមជនអគតិមួយចំនួនដែលតែងតែកុហក បោកប្រាស់ មួលបង្កាច់ខុសពីការពិតមកលើរាជរដ្ឋាភិបាលនាពេលកន្លងមក ហើយក៏កាន់តែបង្ហាញឲ្យឃើញកាន់តែច្បាស់ដោយឥតប្រកែកបានអំពីនយោបាយបោកប្រាស់ក្នុងគោលបំណងបម្រើអាជីវកម្មនយោបាយដ៏ងប់ងល់របស់ពួកខ្លួន ដោយមិនគិតអំពីផលប្រយោជន៍ដ៏ឧត្តុងឧត្តមរបស់ជាតិ មាតុភូមិ និងប្រជាពលរដ្ឋ។

ជាថ្មីម្តងទៀត តាងនាមថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់ សូមប្រកាសគាំទ្រយ៉ាងឧឡារិកចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយគតិបណ្ឌិតខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលតែងតែបានបូជា កម្លាំងកាយ កម្លាំងចិត្ត និងប្រកាន់ភ្ជាប់នូវឧត្តមគតិស្នេហាជាតិដ៏ឧត្តុងឧត្តម ក្នុងការការពារបូរណភាពទឹកដី និងអធិបតេយ្យជាតិជាពិសេសក្នុងការដោះស្រាយបញ្ហាព្រំដែនជាមួយប្រទេសជិតខាងប្រកបដោយការទទួលខុសត្រូវខ្ពស់ចំពោះជោគវាសនារបស់ប្រទេសជាតិ និងមាតុភូមិទាំងមូល។

យើងខ្ញុំទាំងអស់គ្នាជាថ្នាក់ដឹកនាំក្រសួងការពារជាតិ ព្រមទាំងនាយទាហាន នាយទាហានរង និងពលទាហាន នៃកងយោធពលខេមរភូមិន្ទទាំងអស់សូមធ្វើការថ្កោលទោសយ៉ាងដាច់អហង្ការ ចំពោះទង្វើរបស់ជនអគតិមួយចំនួនដែលតែងតែបានធ្វើការប្រឌិត និងចោទប្រកាន់មួលបង្កាច់ទាំងងិតងងល់នាពេលកន្លងមក ដើម្បីបម្រើនយោបាយប្រជាភិថុតរបស់ក្រុមខ្លួនមកលើកិច្ចខិតខំប្រឹងប្រែងយ៉ាងស្មោះសរ និងដើម្បីឧត្តមប្រយោជន៍ជាតិរបស់រាជរដ្ឋាភិបាលលើការងារព្រំដែននេះ និងសូមអំពាវនាវឲ្យមានការចាត់វិធានការផ្លូវច្បាប់ឲ្យបានម៉ឺងម៉ាត់បំផុតដើម្បីពង្រឹងនីតិរដ្ឋក្នុងគោលបំណងថែរក្សាសន្តិភាព ស្ថិរភាពសង្គម សណ្តាប់ធ្នាប់សាធារណៈ និងដើម្បីភាពសុខក្សេមក្សាន្តរបស់ប្រជាពលរដ្ឋ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី០៤ ខែកញ្ញា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

នាយឧត្តមសេនីយ៍ **ទៀ បាញ់**

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារៈ ០២៣ ៨៨៣ ២៧៤ អ៊ីមែលៈ generalsec@mod.gov.kh